# រដ្ឋប្រហារនៅក្នុងរដ្ឋប្រហារ

## បញ្ហាខ្មែរតាមក្រសែភ្នែកលោកគីស្សីងគ្ញើរ

## COUP within the COUP

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី២៥ មករា ២០០៦

**សង្គ្រាមនៅកម្ពុជា ~ ឈុតទី២** ៖ រដ្ឋប្រហាររបូតរលូត ដើម្បីទម្លាក់លន់-នល់ ហើយយកសីហនុពីប៉េកាំងមកដឹកនាំពួកសាធារណរដ្ឋ ។

ក/ «សាធារណរដ្ឋខ្មែរ»កើតឡើងហើយ តែគ្មាននរណាចិញ្ចឹម ៖

ទី១- របបសាធារណរដ្ឋរបស់លោកលន់-នល់ គ្រាន់តែកើតឡើងភ្លាម មិនទាន់រឹងដៃជើងផង ស្រាប់តែយួនខាងជើងនិងយៀកកុង (មាន៣០០,០០០នាក់ យោងតាមសេចក្ដីបញ្ជាក់របស់លោកគីស្សឹងគ្ញើរ) មកឡោមព័ទ្ធរុំស្ទួតជុំជិត ។ ក្នុងសម័យនោះ យួនខាងជើងបានទទួលជំនួយកប់ក្ដោងពីប្រទេសចិន ហើយនិងសហភាពសូវៀត, ចំណែកឧត្តមសេនិយលន់-នល់ ដែលស្ដេចសីហនុមួលបង្កាច់ថា បាន«លក់ខ្លួនឲ្យអាមេរិកាំង ដើម្បីប្រាក់ដុល្លារ» ពុំបានទទួលប្រាក់សូម្បីតែមួយដុល្លារផងទេពីរដ្ឋការនិចសុន ។ នេះមិនមែនជាការអះអាងរបស់យើងទេ តែជាសំណេររបស់លោកគីស្សឹងគ្ញើរផ្ទាល់ នៅក្នុងសៀវភៅ «បញ្ចប់សង្គ្រាមនៅវៀតណាម» ទំព័រ ១៤០ ៖

«មកដល់ពាក់កណ្ដាលខែមេសាទៅហើយ ពេលគឺជាងមួយខែ បន្ទាប់ពីពួកខ្មែរធ្វើរដ្ឋប្រហារ សហរដ្ឋអាមេរិកមិនបានលើកម្រាមដៃមួយផងទេ ។ រដ្ឋប្រហារនេះស្រាប់តែវាមកដល់ភ្លាមមួយរំពេច ដោយគ្មានឲ្យដំណឹងជាមុនសោះ ។ លទ្ធផលនៃរដ្ឋប្រហារនេះ គឺមិនត្រឹមតែមានការគំរាមកំហែង ទៅលើឯករាជភាពនៃប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែវាបណ្ដាលឲ្យខូចខាតដល់គោលជំហររបស់យើងទាំងមូលនៅវៀតណាម...» ។

ដូច្នេះ អាមេរិកាំងដែលបាននាំភ្លើងសង្គ្រាមមកដុតប្រទេសកម្ពុជា នៅពេលដែលខ្មែរកំពុងតែស្លាប់... ពុំបានលើកម្រាមដៃមួយ ដើម្បីជួយសង្គ្រោះជនជាតិខ្មែរនោះផងទេ ។

ទី២- តាមសំណេររបស់លោកគីស្សឹងគ្ញើរនៅក្នុងសៀវភៅដដែល មានតែប្រ

ធានាធិបតីនិចសុនប៉ុណ្ណោះទេ ដែលជួយឈឺឆ្អាលរឿង«សាធារណរដ្ឋខ្មែរ»...ប៉ុន្តែកូនចៅរបស់លោកស្ទើរគ្រប់ក្រសួង បានក្បត់ឬធ្វើវិច្ឆេតកម្មចំពោះបទបញ្ជារបស់លោកប្រធានាធិបតី ។ ជាពិសេសលោកនិចសុនបានបញ្ជាឲ្យក្រសួងសេ.ស៊ី.អា.ផ្ដល់ជំនួយប្រាក់៥លានដុល្លារ (តាមរយៈប្រទេសទី៣) ទៅរបបលន់-នល់ជាបន្ទាន់ដើម្បីកុំឲ្យរបបនេះដាច់ខ្យល់ស្លាប់ ក្រោមការវាយប្រហាររបស់យួន ។ ប៉ុន្តែប្រាក់នេះ មិនដែលបានទៅដល់ដៃរបស់លោកលន់-នល់សោះ (ប្រាក់នេះសំរាប់ទិញអាវុធនៅផ្សារងងឹត... គ្រាន់តែជាទឹកមួយដំណក់ក្នុងជំនួយអាមេរិកាំង) ។

នៅទំព័រ១៩០ នៃសៀវភៅ «បញ្ចប់សង្គ្រាមនៅវៀតណាម» លោកគីស្សីងគ្ញើរបានសរសេរថា ៖

«មកទល់ពេលនេះ គេអាចមើលឃើញអាកប្បកិរិយាឈ្លានពានរបស់ហាណូយយ៉ាងច្បាស់លាស់ ។ កងកម្លាំងវៀតណាមខាងជើងកំពុងធ្វើការវាយប្រហាររាតទឹកដីទៅលើកម្ពុជាទាំងមូល ជាពិសេសដោយប្រមូលផ្ដុំកម្លាំង សំរុកទៅលើទីរួមខេត្តនានា ព្រមទាំងកាត់ផ្ដាច់គមនាគមន៍ពីក្រុងភ្នំពេញ ។

«តទល់នឹងការគំរាមកំហែងរបស់យួនខាងជើង ដែលមានកំរិតកាន់តែខ្ពស់ឡើងនេះ លោកប្រធានាធិបតី (និចសុន) កាន់តែមានការខកចិត្តខ្លាំងឡើង ហើយលោកក៏បានធ្វើចំណាត់ការផ្ទាល់ខ្លួន ដើម្បីប្រញាប់ប្រញាល់ផ្ដល់ជំនួយទៅប្រទេសកម្ពុជា ។ នៅពេលជំនួបមួយជាមួយនឹង Helms ហើយនិងឧត្ដមសេនិយ Robert Cushman (នាយករងនៃសេអ៊ីអា) នៅថ្ងៃទី១៦ មេសា (១៩៧០) ធ្វើឡើងនៅក្នុងគោលបំណងរៀបចំដាក់ស្ថានិយសាខាមួយនៃក្រសួងសេអ៊ីអានៅទីក្រុងភ្នំពេញ, លោកនិកសុនបានបញ្ជាឲ្យប្ដល់ជំនួយកញ្ចប់អាវុធពិសេស សំរាប់មនុស្ស១,០០០នាក់ (1,000 man packs) ។ ពីរបីថ្ងៃក្រោយមក លោកបានតម្លើងប្រាក់ជំនួយសម្ងាត់ពី៥លានទៅ១០លានដុល្លារ ដែលយល់ព្រមដោយ WSAG ។ តាមការពិតបទបញ្ជាទាំងនេះ មិនបានទទួលការអនុវត្តន៍ទេ ដោយសារតែមានការបង្កើនវាយសំរុកពីសំណាក់ហាណូយ ហើយនិងសេចក្ដីសំរេចរបស់លោកនិចសុន២សប្ដាហ៍ក្រោយមកក្នុងប្រការធ្វើចលនា (វាយកំទេច) ទីកន្លែងជំរករបស់ពួកយៀកកុង (<u>កកន</u> ៖ តើជំនួយទៅប្រទេសខ្មែរ វាមានបុកប្រឆាំងឬក៏ប៉ះទង្គិចយ៉ាងណា ជាមួយនឹងការវាយកំទេចជំរំយោធាពួកយួនកុម្មុយនិស្ត ?)....។

នៅទំព័រ១៨៩នៃសៀវភៅដដែល លោកគីស្សីងគ្ញើរបានសរសេរថា ៖

«នៅពេលត្រឡប់មកក្រុងវ៉ាស៊ិនតោនវិញ ជំហានទី១របស់លោកនិចសុន គឺបើកការប្រជុំមួយជាមួយនិង Helms ហើយនិងរូបខ្ញុំនៅម៉ោង៧ព្រឹកនៃថ្ងៃទី២១មេសា ។ Helms ក៏ធ្វើ<ប្រ៊ីហ្វីង> (របាយការណ៍ដោយបំព្រួញសេចក្ដី) ថា ពួកវៀតណាមខាងជើងកំពុងតែវាយប្រហារលាតសន្ធឹង ទៅលើប្រទេសកម្ពុជាទាំងមូល ហើយថាទីក្រុងភ្នំពេញមិនអាចធុនទ្រាំនឹងការវាយប្រហារនេះបានទេ ។ ដោយពី-

ព្រោះអំពីលក្ខន្តិកៈនៃការតបឆ្លើយដ៏បន្តិចបន្តួចរបស់យើង លោកនិចសុនគ្រាន់តែបានសង្កេតឃើញថា ទឹកប្រាក់៥លានដុល្លារសំរាប់ទិញអាវុធ ដែលយល់ព្រមដោយ WSAG កាលពីថ្ងៃទី១៥មេសា ហើយដែលលោកបានតម្លើងមួយជាពីរនៅពេលបន្ទាប់មក នៅផ្អាប់ទុកនៅមួយកន្លែងដដែល ដោយសារតែការដំអែដំអក់របស់ក្រុមក្រសួងការិយាល័យ ។ ចំណែកគ្រឿងសម្ភារៈទំនាក់ទំនងសេអ៊ីអា ដែលលោកអនុញ្ញាតឲ្យផ្តល់ តាំងពីថ្ងៃទី១មេសា ហើយដែលលោកបានតឿនថែមទៀតនៅថ្ងៃទី១៦មេសា ក៏ពុំបានធ្លាក់ទៅដល់ដៃខ្មែរផងដែរ (<u>កកន</u> ៖ ដូច្នេះក្រសួងសេអ៊ីអា ដែលស្តេចសីហនុហើយនិងទីក្រុងហាណូយបានចោទប្រកាន់ថា ជាអ្នកផ្តួចផ្តើមឧត្តមសេនិយលន់-នល់ ឲ្យធ្វើរដ្ឋប្រហារទម្លាក់ស្តេច... មិនព្រមទាំងបញ្ជូនប្រាក់៥លានដុល្លាររបស់ប្រធានាធិបតីនិចសុន ទៅដល់សាធារណរដ្ឋខ្មែរផង ។ ដូច្នេះសៀវភៅរបស់ស្តេចសីហនុ «សង្គ្រាមរបស់ខ្ញុំតទល់នឹងសេអ៊ីអា» (My war with the CIA) គឺជាមហាកំពែងនៃសេចក្តីភរភូត» Un Monument du Mensonge របស់ស្តេចសីហនុ, យួនហាណូយ ហើយនិងអាមេរិកាំងផងដែរ ។ គឺបានសេចក្តីថា រដ្ឋប្រហារនៅប្រទេសកម្ពុជាទាំងប៉ុន្មាន ចាប់តាំងពីរដ្ឋប្រហារដាបឈួន, រដ្ឋប្រហារសម-សារី, រដ្ឋប្រហារលន់-នល់... គឺមានអាមេរិកាំងជាអ្នកផ្តួចផ្តើមធ្វើទាំងអស់ ប៉ុន្តែខុសពីការស្មានរបស់អ្នកផង រដ្ឋប្រហារទាំងនេះធ្វើឡើង សំរាប់តែជួយពង្រឹងជំហររបស់ស្តេចសីហនុនិងក្រុងហាណូយតែប៉ុណ្ណោះ ។ នៅទំព័រ១២៧នៃសៀវភៅដដែល លោកគីស្សីងគ្ជើរបានសរសេរថា ៖ «នៅពេលដែលលោកប្រធានាធិបតីនិចសុនជួបនិងលោកប្រធានាធិបតីធីវនៅក្រុងព្រៃនគរថ្ងៃ៣០ កក្កដា ១៩៦៩, លោកធីវបានធ្វើការទស្សន៍ទាយដូចដឹងជាមុនថា ប្រសិនបើលំនឹងនៃប្រទេសកម្ពុជាត្រូវបាត់បង់ដោយសារការទម្លាក់សីហនុ ពួកកុម្មុយនិស្តនឹងច្បាស់ជាឈ្នះនៅពេលចុងចប់» ។ នៅថ្ងៃ៣០ កក្កដា ១៩៦៩, លោកលន់-នល់ មិនទាន់បានត្រូវតែងតាំងជារដ្ឋមន្ត្រីទី១នៅឡើយទេ... ចុះហេតុអ្វីបានជាលោកធីវ នៅព្រៃនគរដឹងមុនពីការទម្លាក់ស្តេច ? ដូច្នេះ... ការទម្លាក់ស្តេចនេះ គឺមានតែអាមេរិកាំង-យួនជាអ្នកធ្វើ ដោយគ្មានពាក់ព័ន្ធនឹងលន់-នល់ទេ !) ។

⋆⋆⋆ ដូច្នេះនៅចុងខែមេសា១៩៧០ ពេលដែលយួនខាងជើងវាយសំរុកប្រទេសកម្ពុជា ស៊ីរូងដល់ថ្លើមប្រមាត់ ពោលដល់ស្អាងនិងគគីរធំទៅហើយ (តែ៩-១០ គីឡូម៉ែត្រពីភ្នំពេញប៉ុណ្ណោះ) សហរដ្ឋអាមេរិកបែរជាដំអក់ឈរមើល ទុកឲ្យសាធារណរដ្ឋខ្មែររបស់លោកលន់-នល់ដាច់ខ្យល់ស្លាប់ ។ អាក្រក់ជាងនេះទៅទៀត គឺអាមេរិកាំងកំពុងតែចងដៃខ្មែរឲ្យយួនសម្លាប់ !!

⋆⋆⋆ ដូច្នេះនៅពេលដែលសាធារណរដ្ឋរបស់លោកលន់-នល់ សុំជំនួយសេដ្ឋកិច្ចអាមេរិកាំងនិងជំនួយយោធាសំរាប់បង្កើនកងពល២០០,០០០នាក់ រដ្ឋការនិចសុនបានសំរេចផ្តល់ប្រាក់តែ៥លានដុល្លារប៉ុណ្ណោះ ពោលគឺទឹកមួយដំណក់សំរាប់

ប្រទេសកម្ពុជាដែលកំពុងត្រដរខ្យល់ ក្រោមការវាយលុករាតត្បាតដ៏មហាសស្សារព្ពីសំណាក់យៀកកុងនិងយួនខាងជើង ។ នៅទីបំផុតប្រាក់៥លានដុល្លារក៏អត់, ទឹកមួយដំណក់ក៏អត់... សូម្បីតែមួយសេនរបស់អាមេរិកាំង ក៏មិនបានមកដល់ដៃខ្មែរដែរ (នៅរយ:ពេលពីរបីខែដំបូងនៃរបបសាធារណរដ្ឋ) ។

❑

❑ ❑

ខ/ អាមេរិកាំងជាអ្នកបុលបរាជ័យទៅដល់សាធារណរដ្ឋខ្មែរ ៖

នៅក្នុងមតិមហាជនអាមេរិកាំង - វិទ្យុ - ទូរទស្សន៍ - សារពត៌មាន គេពោលសរសើរលើកដម្កើងតែស្តេចសីហនុ ហើយបន្ទុះបង្អាប់បន្ថោកបន្ទាបតែទៅលើឧត្តមសេនិយលន់-នល់ ។ ចរន្តសីហនុនិយមនេះ (យៀកកុងនិយម) បានឆ្លងរាលដាលដល់មតិពិភពលោកទាំងមូល, ដល់សភាអាមេរិកាំង, ដល់កាសែត New York Times, ដល់កាសែតបារាំង Le Figaro, Le Monde, Le Nouvel Observateur... Jeune Afrique ។ ហេតុការណ៍ទាំងនេះ គឺជាស្នាដៃរបស់លោកគីស្សីងហ្គើរ ។ គឺលោកគីស្សីងហ្គើរខ្លួនឯងដែលបានសរសេរ (នៅទំព័រ៦៧នៃសៀវភៅ «បញ្ចប់សង្គ្រាមនៅវៀតណាម») នូវការសង្កេតដូច្នេះថា ៖

«ចំនួនជាង១០ឆ្នាំមកហើយ (រហូតមកទល់ថ្ងៃ១៨ មិនា ១៩៧០) សីហនុបានសំដែងនូវការវៃឆ្លាតនិងប៉ិនប្រសប់ខាងថ្លឹងថ្លែងនយោបាយផ្ទៃក្នុង ជាមួយនឹងការសម្ពាធពីបរទេស ។ ក្នុងវង្សត្រកូលក្សត្រតពូជមួយអង្គ នរោត្តម-សីហនុបានរៀបចំឲ្យមានឯករាជភាពនៃប្រទេសរបស់ទ្រង់ ព្រមទាំងបានទទួលនូវបារមីអំណាច ដែលធ្វើឲ្យអ្នកផងចៀសវាងព្រះអង្គមិនបាន ។ ទ្រង់បានធ្វើនយោបាយការពារប្រទេសរបស់ទ្រង់ មិនឲ្យធ្លាក់ចូលក្នុងសង្គ្រាមឥណ្ឌូចិន» (sic!) ។

អាមេរិកាំងកំពុងតែច្បាំងជាមួយនឹងសីហនុហើយនិងយៀកកុងទេតើ ហេតុអ្វីបានជាលោកគីស្សីងហ្គើរបែរជាលើកសីហនុខ្ពស់ហួសពពកយ៉ាងនេះ ? ការថ្លែងសរសើរស្តេចសីហនុបែបនេះ គឺជាការលើកដម្កើងយៀកកុងដោយចំពោះ ព្រមទាំងជាការរុញច្រានឲ្យសាធារណរដ្ឋខ្មែរទទួលបរាជ័យ ។

មិនត្រឹមតែប៉ុណ្ណោះ លោកគីស្សីងហ្គើរបានយកលិខិត ដែលស្តេចសីហនុបានផ្ញើទៅពួកម៉ាករបស់គាត់ គឺសមាជិកព្រឹទ្ធសភា Mike Mansfield... ហើយដែលបានប្រៀបធៀបលោកលន់-នល់ទៅនឹង Hitler ជាជនហ្វាស៊ីស ស្រេកឃ្លានសង្គ្រាមនិងការកាប់សម្លាប់ យកទៅធ្វើសម្ពាធលើប្រធានាធិបតីនិចសុន ។ នៅទីកន្លែងណាក៏ស្តេចយៀកកុងនរោត្តម-សីហនុលេចឡើងជាទេព្ត ស្រឡាញ់តែសន្តិភាព ប្រកបដោយ «អំណាចបារមី ដែលគេចៀសមិនរួច» ។

នៅក្នុងពេលជាមួយគ្នានោះ ក្រសួងសេអ៊ីអា ក៏បានផ្សាយរបាយការណ៍មួលបង្កាច់ដ៏ថោកទាបមួយទៅលើឧត្តមសេនិយលន់-នល់ ដោយចោទថា ៖ «តាំងពីឆ្នាំ

១៩៦៧ លន់-នល់ជាអ្នកបានទទួលផលចំណេញ ក្នុងប្រការដឹកគ្រឿងអាវុធនិងស្បៀងទៅឲ្យយៀកកុង» (<u>កកន</u> ៖ ខ្ញុំនៅចាំច្បាស់ណាស់ដូចកាលពីថ្ងៃម្សិលមិញ... ពេលនៅចុងឆ្នាំ១៩៦៦ ខ្ញុំធ្វើជាលេខាធិការរបស់លោកស៊ឹម-វ៉ារ ដែលជាឧបនាយករដ្ឋមន្ត្រីនៅក្នុងរដ្ឋាភិបាលលន់-នល់ទី១ ។ ខ្ញុំនៅចាំថា ពេលនោះលោកលន់-នល់បានបាត់បង់តំណែងពីរ ដែលជាខែលការពារខ្លួនគាត់ គឺតំណែងរដ្ឋមន្ត្រីការពារប្រទេស ហើយនិងអគ្គបញ្ជាការកងទ័ព ។ នៅក្នុងខែមេសា១៩៦៧ លោកលន់-នល់បានទទួលគ្រោះថ្នាក់ក្រឡាប់ឡាន ហើយបាត់បង់តំណែងនាយករដ្ឋមន្ត្រី ។ ម៉្លោះហើយនយោបាយដឹកនាំប្រទេសកម្ពុជា បានធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ក្រុមបំរើរបស់ស្តេចស្រីយៀកកុងម៉ូនិក-អ៊ីស៊ីទាំងអស់... ពោលគឺសម្តេចប៉ែន-នុត, សម្តេចសឺន-សាន, សម្តេចជូឡុង ។ សម្តេចទាំងបីនេះ សុទ្ធសឹងជារនុកក្នុងរបស់យួន)។

★★★ អស្ចារ្យណាស់ ! សម្តេចសីហនុបានចោទថា លន់-នល់ជាអ្នកបំរើសេអ៊ីអា... ចំណែកក្រុមសេអ៊ីអាបានចោទថា លោកលន់-នល់ជាអ្នកបំរើយៀកកុង ។ អាយ៉ៃឆ្លងឆ្លើយនេះ ជារឿងកំប្លុកកំប្លែងគួរឲ្យចង់សើចពន់ពេក... ប្រសិនបើពុំមានខ្មែរបីលាននាក់រងគ្រោះស្លាប់ នៅក្នុងសង្គ្រាមប្រល័យពូជសាសន៍មួយដ៏មហាអាណោចអធ៌ម ដែលមានអាយុ៣០ឆ្នាំ ។

នៅទីបំផុត ដោយសារនយោបាយបត់បែនទុច្ចរិតរបស់គីស្ស៊ីងគ្ញើរ សភាអាមេរិកាំងក៏បានសំរេចប្តល់ជំនួយឲ្យសាធារណរដ្ឋខ្មែរតែ២០០លានដុល្លារប៉ុណ្ណោះ គឺមិនបានទាំង១/១០០ នៃជំនួយដែលសហរដ្ឋអាមេរិកផ្តល់ឲ្យរដ្ឋការព្រៃនគរផង (បីពាន់លានដុល្លារ) ។ ជំនួយជួយខ្មែរ គឺសំរាប់តែបង្កើតកងទ័ព គឺមិនឲ្យខ្មែរស្លាប់ ហើយក៏មិនឲ្យខ្មែររស់ ។ ទីក្រុងខ្មែរទាំងប៉ុន្មានត្រូវដាច់គមនាគមន៍ពីជនបទ ដោយសារតែការវាយប្រហាររបស់យៀកកុង ។ សាធារណរដ្ឋខ្មែរគ្មានសេដ្ឋកិច្ច គ្មានជំនួញជួញដូរអ្វីទៀតទេ... គឺមានតែការរត់ពន្ធដើម្បីចិញ្ចឹមក្រពះ ។ អ្នកស្រុកជនបទទូទៅបាត់បង់កិច្ចការងារជាកសិករ ។ មួយចំនួនធំដែលទទួលរងគ្រោះ ដោយសារការរាតត្បាតរបស់យៀកកុង បានរត់ចូលទីក្រុង ដើម្បីបំរើកងទ័ពលន់-នល់ ។ មួយចំនួនទៀតដែលទទួលរងគ្រោះដោយសារគ្រាប់បែកអាមេរិកាំង និងការប្លន់រឹបអូសពីសំណាក់រដ្ឋការយួនខាងត្បូង ក៏បានរត់ចូលទៅក្នុងជួររបស់ប៉ុល-ពត ។ ដោយសារតែនយោបាយជួញសង្គ្រាមរបស់សីហនុ-គីស្ស៊ីងគ្ញើរ ប្រជាជាតិខ្មែរក្នុងឆ្នាំ១៩៧០ ក៏បានធ្លាក់ចូលក្នុងមហន្តរាយ ។

២- <u>គីស្ស៊ីងគ្ញើរជាអ្នកបង្ខំលន់-នល់លើកទង់ជ័យស (ចុះចាញ់ដោយឥតប្រយុទ្ធ)</u> ៖

នៅក្នុងឆ្នាំ១៩៧២ សាធារណរដ្ឋខ្មែរបានបង្ហាញនូវសញ្ញានៃការទ្រុឌទ្រោម ។ ប្រជាជននៅទីក្រុងគ្មានប្រាក់ចំណូល ក្រៅតែពីជំនួយអាមេរិកាំង ។ យុទ្ធជនរបស់លោកលន់-នល់ចាប់ផ្តើមមានការហត់នឿយនឹងសង្គ្រាមវាយឆ្មក់របស់ពួកកុម្មុយនិ

ស្ពបិទផ្លូវ-បើកផ្លូវ (ជាពិសេសត្រូវបាក់ទ័ពនៅចេនឡាទី២) ប៉ុន្តែហត់នឿយជាទីបំផុត គឺនៅក្នុងរង់ចាំប្រាក់បៀវត្ស ដែលក្រុមកដល់ ។ លោកមេទ័ព (នាយសេនាធិការ) សុស្តែន-ហ្វែរណង់ដែស រត់ពន្ធស្រាចូលភ្នំពេញទាំងកណ្តាលថ្ងៃត្រង់ ហើយឲ្យកងទ័ពខ្លួនទៅព័ទ្ធលោកកុម្មីស្សែរ-សង់ត្រាល់ ជា-គឹមអេង ប្រហែលគ្នានឹងគេធ្វើរដ្ឋប្រហារ ។ លោកមេតំបន់ខ្សែក្រវាត់ជុំវិញភ្នំពេញ ឧត្តមសេនិយ ហ៊ូវ-ហាំងស៊ិន (R.M.S. - Région Militaire Spéciale) បានក្លាយទៅជាតំបន់យៀកកុង ៖ ម៉ូនិក-សីហនុ (Région Monique Sihanouk) ។ គឺហ៊ូវ-ហាំងស៊ិននេះហើយ ដែលបានអនុញ្ញាតឲ្យកុម្មង់ដូយៀកកុង ចូលកំទេចយន្តហោះទាំងអស់នៅពោធិចិនតុង (១៩៧១) ជាបុព្វហេតុបណ្តាលឲ្យលោកលន់-នល់ដាច់សរសៃក្បាល ។ នៅទីណាក៏ពួកមេទាហានរេចូលស្តេចដែរ ៖ ហែម-ស៊ីវេត, ថោង-វ៉ាន់ហ្វាន់មឿង, នរោត្តម-ចន្ទរង្សី..។ ទាហានអាកាសចរណ៍ សុភុត្រា (កូនប្រសាររបស់ស្តេចសីហនុ) បានទម្លាក់គ្រាប់បែកទៅលើវិមានរដ្ឋចំការមន ដែលលោកលន់-នល់ស្នាក់នៅ... រួចក៏ហោះសំដៅទៅប៉េកាំង (វាទាល់តែអាមេរិកាំងបិទភ្នែក ទើបបានយន្តហោះនេះ (យន្តហោះសង្គ្រាមលោកលើកទី២ T-28) រត់រួចទៅដល់ប៉េកាំង) ។

នៅកណ្តាលក្រុងភ្នំពេញ គេឃើញឡានឃោធាដឹកយុទ្ធជនរបួសជាអចិន្ត្រៃយ៍ ។ នៅក្នុងពេលជាមួយគ្នានោះ ទំនិញបានឡើងថ្លៃកប់ពពក, ពងមាន់មួយដែលធ្លាប់មានតម្លៃតែ៣រៀល បានឡើងថ្លៃដល់ទៅ៥០រៀល ។ ប្រាក់១ដុល្លារដែលធ្លាប់មានតម្លៃ៣៥រៀល ក៏បានឡើងរហូតដល់ទៅ៥០០រៀល ។ ប្រជាជនខ្មែរមិនដែលហូបសាច់ឆ្កែទេ ប៉ុន្តែនៅក្នុងឆ្នាំ១៩៧២ គេមិនដែលឃើញមានសត្វឆ្កែមួយដើររហេតរហូតនៅតាមផ្លូវនៅភ្នំពេញទាល់តែសោះ (ពីដើមចំនួនឆ្កែរសាត់អណ្តែតមាន៥ម៉ឺនក្បាលនៅក្នុងរាជធានី) ។ ម្ល៉ោះហើយ សារពត៌មានសេរីនៅក្នុងពិភពលោកទាំងមូល ក៏សរសេរតាមគ្នាត្រូសងថា កាលពីសម័យស្តេចសីហនុ ប្រទេសកម្ពុជាមានសន្តិភាពសំបូរសប្បាយ មានអង្ករហូបគ្រប់គ្រាន់ ដល់មកសម័យលន់-នល់ ស្រាប់តែប្រជាជនខ្មែរក្លាយទៅជាអ្នកសុំទាន (គ្មាននរណាម្នាក់និយាយពីស្តេចសីហនុ ហៅអាមេរិកាំងឲ្យទម្លាក់គ្រាប់បែក... ហើយហៅយៀកកុងឲ្យមកវាយកំទេចប្រទេសខ្លួនឯងនោះទេ - គ្មាននរណាម្នាក់បានសរសេរថា ស្តេចសីហនុជាឃាតករសម្លាប់ខ្មែរ ហើយជេរខ្មែរថា «ពួកអាស្លាប់», «ពួកអាសុំទាន» នោះទេ) ។

នៅនយោបាយកំពូលលើ ក៏មានការបែកបាក់គ្នាដោយចៀសមិនរួច ។ អ្នកដឹកនាំនៅភ្នំពេញក៏មានចែកគ្នាជាបីក្រុម ៖ ពួកក្រុមសាធារណរដ្ឋ មានលោកលន់-នល់, សឺង-ង៉ុកថាន់, ហង្ស-ធុនហាក់, លន់-ណុន ។ ពួកក្រុមកម្លាំងទី៣ (Troisième force) ៖ ទាមទារហៅស្តេចសីហនុមកវិញត្រង់ៗតែម្តងមាន អ៊ិន-តាំ, ឌុក-រ៉ាស៊ីចៅ-សៅ, កែវ-អន ។ ពួករាជានិយម ដែលធ្វើការជាសម្ងាត់ជាមួយអាមេរិកាំង ដើម្បីទម្លាក់លន់-នល់ ហើយយកស្តេចសីហនុមកវិញ ៖ មានទ្រង់ស៊ីសុវត្ថិ-សិរិម

គ:, ឡុង-បូរ៉េត, ទ្រិញ-វ៉ាញ, ឱប-គីមអាន, យ៉ៃម-សំបូរ ដោយរួបរួមគ្នាជាមួយមេទ័ពសុស្តែន-ហ្វែរណង់ដែស និងនរោត្តម-ចន្ទរង្សី ។

គឺចំពេលនោះតែម្តង ដែលលោកគីស្សីងគ្ញើរបង្ខំលោកលន់-នល់ឲ្យផ្អាកសង្គ្រាមដោយគ្មានការចរចា ពោលគឺបញ្ឈប់ចំបាំងតែពួកខាងសាធារណរដ្ឋ គឺដូចឲ្យលោកលន់-នល់លើកទង់ជ័យសចំពោះស្តេចសីហនុ ហើយនិងពួកខ្មែរក្រហមអីចឹងឯង ។ ត្រង់កន្លែងនេះ សូមពួកយើងកុំភ្លេចឆ្ងល់ គឺគីស្សីងគ្ញើរនេះហើយដែលបានរៀបចំជនជាតិខ្មែរ ឲ្យធ្លាក់ទៅក្នុងផ្លូវមហន្តរាយនៃថ្ងៃ១៧ មេសា ១៩៧៥ ។ គឺលោកគីស្សីងគ្ញើរនេះហើយ ដែលបានចងដៃពួកសាធារណរដ្ឋខ្មែរ ឲ្យពួកកុម្មុយនិស្តសម្លាប់ ប្រហែលគ្នានឹងសត្វឆ្កែ ឬសត្វជ្រូក...។

តាមពិតលោកគីស្សីងគ្ញើរបានទទួលការញុះញង់ពីយួនខាងជើងទៅវិញសោះ (ថ្ងៃទី២២ តុលា ១៩៧២) ។ នៅទំព័រ៣៦៣នៃសៀវភៅ «បញ្ចប់សង្គ្រាមនៅវៀតណាម» លោកគីស្សីងគ្ញើរបានសរសេរថា ៖

«ហាណូយមានការទុកចិត្តអំពីឥទ្ធិពលរបស់ខ្លួន ទៅលើបក្សសម្ពន្ធនៅលាវ គឺពួកប៉ាថេតឡាវ ។ ម៉្លោះហើយ ឡេ-ឌឹកថបានសន្យានឹងធ្វើឲ្យមានការឈប់បាញ់គ្នានៅលាវ តែក្នុងរយៈពេល៣០ថ្ងៃប៉ុណ្ណោះ បន្ទាប់ពីវៀតណាមទាំងសង្ខាងសុខចិត្តយល់ព្រមចុះហត្ថលេខា បញ្ឈប់ការប្រទុស្តរាយគ្នា ។ ឡេ-ឌឹកថបានសន្យាបន្ថែមទៀតថា នឹងប្រគល់អ្នកទោសសង្គ្រាម (អាមេរិកាំង) នៅលាវ... ស្របគ្នានឹងការប្រគល់អ្នកទោសសង្គ្រាមនៅវៀតណាម ។ គាត់នេះបានបញ្ជាក់ថា ពុំមានអ្នកទោសសង្គ្រាមនៅប្រទេសកម្ពុជាទេ ។ ចំពោះប្រទេសកម្ពុជា ឡេ-ឌឹកថបានបញ្ជាក់ថា ខ្លួនពុំសូវមានឥទ្ធិពលទៅលើពួកខ្មែរក្រហមប៉ុន្មានទេ ។ គាត់នេះគ្រាន់តែបានអះអាងតាមមាត់ថា ពេលណាមានបញ្ចប់សង្គ្រាមនៅលាវនិងវៀតណាមហើយ «វាគ្មានរឿងអ្វីដែលសង្គ្រាមត្រូវបន្តនៅប្រទេសកម្ពុជានោះទេ» ។ បន្ទាប់ពីខ្ញុំតឿនច្រើនដងឲ្យមានការសន្យាឈប់បាញ់គ្នានៅប្រទេសកម្ពុជាផងដែរ...។ ក្រុងហាណូយគ្រាន់តែបានសរសេរជាលាយលក្ខអក្សរ អំពីអ្វីដែលឡេ-ឌឹកថបានសន្យានឹងខ្ញុំតាមមាត់ប៉ុណ្ណោះ ។ ខ្ញុំក៏បានសំរេចតឿនបង្ខំឲ្យលន់-នល់បញ្ឈប់ការបាញ់គ្នា តែខាងពួកសាធារណរដ្ឋប៉ុណ្ណោះ (Unilateral cease-fire) នៅពេលដែលមានការចុះហត្ថលេខាព្រមព្រៀងនៅសន្និសិទក្រុងប៉ារីស...» (កកន ៖ គ្មានវាចានឹងថ្លែង) ។

❑

❑ ❑

គ/ ឆ្នាំ១៩៧៥ សាធារណរដ្ឋខ្មែរដាច់ខ្យល់...សីហនុក៏មិនបានត្រឡប់មកវិញ ៖

នៅដើមឆ្នាំ១៩៧៥, ខ្មែរក្រហមកាត់ផ្តាច់គមនាគមន៍នៃទន្លេមេគង្គ នៅតំបន់អ្នកលឿង ។ គ្រាប់រ៉ុក្កែតសូវៀត១២២ ធ្លាក់ចូលក្នុងរដ្ឋធានីភ្នំពេញរាល់ថ្ងៃ... បណ្តាលឲ្យមនុស្សម្នាស្លាប់គរជើងលើគ្នា ។ សភាអាមេរិកាំងក៏បានកាត់ផ្តាច់ជំនួយយោធា (២

រយលានដុល្លារ) ពីសាធារណរដ្ឋខ្មែរ ។ ម្ល៉ោះហើយសាធារណរដ្ឋនេះរង់ចាំតែដាច់ខ្យល់ស្លាប់ ដោយដាច់បន្តោងសេរ៉ូម ។ បើទោះជាយកស្តេចសីហនុមកវិញ ក៏ទ្រង់មិនមែនជាទេព្តាអាចរកថវិកាឯណា ដើម្បីចិញ្ចឹមពួកសាធារណរដ្ឋបានដែរ ។ ប៉ុន្តែលោក John Gunther Dean អគ្គរដ្ឋទូតអាមេរិកាំងនៅតែល្ងីល្ងើពកថ្វាស ដោយជឿថាស្តេចសីហនុ ជាវរជនតែមួយគត់ដែលអាចរកសេចក្តីសុខសន្តិភាពឲ្យខ្មែរវិញ ។ ម្ល៉ោះហើយ លោកធ្វើរដ្ឋប្រហារដោយត្រង់ៗ ដោយកោះហៅមេដឹកនាំគ្រាក់ៗនៅភ្នំពេញទាំងប៉ុន្មាន មកប្រជុំគ្នានៅផ្ទះលោកតែម្តង ។ គោលបំណាងគឺយកលោកលន់នល់ចេញ ហើយយកសីហនុចូល ។

អាមេរិកាំងក៏បានដឹកលោកលន់-នល់ចេញនៅថ្ងៃទី១ មេសា ១៩៧៥... ព្រមទាំងបានដាក់លោកសូ-កាំខូយជំនួសវិញ ។ ជាការឥតអំពើ... ព្រោះសីហនុមិនព្រមនិយាយរកសូ-កាំខូយ ។

នៅទំព័រទី៥២៦នៃសៀវភៅ«បញ្ចប់សង្គ្រាមនៅវៀតណាម» លោកគីស្ស៊ីងគ្ញើរ បានសរសេរថា ៖

«នៅពេលដែលអ្វីៗហៀបតែរលត់រលាយអស់ទៅហើយ ស្រាប់តែស្តេចសីហនុបញ្ចេញសម្លេងឲ្យគេឮឡើងវិញ ៖

- ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ទៅថ្ងៃមុខឆាប់ៗនេះក្តី, ទៅអនាគតវែងឆ្ងាយក្តី... ពួករណសិរ្សកម្ពុជា (ខ្មែរក្រហម) មិនអាចជានាផ្សះផ្សាជាមួយបនសូ-កាំខូយ ហើយនិងប៉ាន់-សូធីនោះទេ» ។

សីហនុថ្លែងសេចក្តីដូចនេះជាផ្លូវការ តែតាមផ្លូវស្ងាត់ បានបញ្ជូនអ្នកនាំសារឈ្មោះ ពុង-ប៉េងចេង (ជាឪពុកអ្នកស្រីក្អែក-កាឡាប្ញូនៅភ្នំពេញសព្វថ្ងៃ) ឲ្យមកជួបលោក Holdridge អ្នកតំណាងអាមេរិកាំងនៅទីក្រុងប៉េកាំងកាលនោះ ឲ្យមកធ្វើសំណើដូចតទៅនេះ ៖

- ជារឿងមួយសំខាន់ណាស់ ដែលត្រូវរកដំណោះស្រាយមួយ ឲ្យបានមុនព្រែនគរធ្លាក់ ។ បើពុំនោះសោតទេ ពួកវៀតណាមខាងជើងនិងខ្មែរក្រហម ច្បាស់ជានឹងវាតយកប្រទេសខ្មែរទាំងមូល ដូចសូវៀតយកឆេកូស្លូវ៉ាគីអឺចឹងឯង ។

«សម្តេចសីហនុពុំមានអំណាចអ្វីទេនៅប៉េកាំង... ទ្រង់មិនអាចធ្វើអ្វីទាំងអស់ដើម្បីជួយប្រទេសកម្ពុជា ។ ប៉ុន្តែទ្រង់មិនចង់ឲ្យពួកខ្មែរក្រហម យកកម្ពុជាទាំងមូលបាននោះដែរ ។

«ក្នុងប្រការនេះ ជាការល្អណាស់ ដើម្បីទុកកងទ័ពឲ្យនៅដដែលនៅកម្ពុជា ។ កងទ័ពនេះ គឺបានសេចក្តីថា កងទ័ពភ្នំពេញ មិនមែនពួកខ្មែរក្រហមនោះទេ...» ។

★★★ ក្នុងប្រការទាក់ទងនឹងសីហនុ អាមេរិកាំងក៏ត្រូវចាញ់បោកពួកចិន ហើយនិងពួកខ្មែរក្រហមបណ្តោយ ។ តើខ្មែរក្រហមមិនមែនជាស្វាឯណា ដែលសុខចិត្តឲ្យសីហនុមកចូលខាងអាមេរិកាំងវិញនោះ ?

នៅថ្ងៃទី១១មេសា លោកពុង-ប៉េងចេងបានយកសំណើមួយទៀតរបស់ស្តេចសីហនុ មកប្រាប់លោក Holdridge... គឺសុំឲ្យលោកសូ-កាំខូយ ដែលសីហនុចោទថាជាជនក្បត់ជាតិនោះ ស្នើសុំឲ្យសីហនុវិលវិញដោយខ្លួនឯង គឺត្រូវឲ្យមាន «ញាតិរបស់សម្តេចសង្ឃទាំងពីរគណៈ, និងប្រតិភូសង្ឃឯទៀតៗឲ្យបានច្រើន, ឲ្យមានក្រុមនិស្សិត ពួកយោធា និងពួកប្រជាកសិករ...» ។

យើងក៏បានដឹងជាបន្តបន្ទាប់មក ថាពួកប្រតិភូលើកទង់ជ័យស ដែលស្នើសុំឲ្យសីហនុត្រឡប់វិញនោះ បានត្រូវពួកខ្មែរក្រហមបាញ់សម្លាប់ចោលទាំងអស់ នៅក្រសួងឃោសនាការនៅថ្ងៃទី១៧ មេសា ១៩៧៥ ។ នៅថ្ងៃនោះ ប្រទេសកម្ពុជាទាំងមូល បានឮសម្លេងខ្មែរក្រហមម្នាក់ផ្សាយចេញពីក្រសួងឃោសនាការ... ហើយដែលព្រមានឧត្តមសេនិយម៉ី-ស៊ីចនថា ៖ «យើងមិនមែនឈ្នះដោយការចរចាទេ គឺឈ្នះដោយចុងអាវុធ!» ។

★★★ យើងក៏ដឹងផងដែរថា វរជនគ្រាក់ជាច្រើនគ្នា មានទ្រង់សិរិមតៈ ហើយនិងលោកឡុង-បូរ៉េតសុខចិត្តក្រាញស្លាប់នៅភ្នំពេញ ក៏ព្រោះតែចាញ់បោកសំណើចុងក្រោយរបស់ស្តេចសីហនុខាងលើនេះឯង ។

តទៅនេះជាសំណោររបស់លោកគីស្សីងគ្មើរ នៅទំព័រទី៥២៩និង៥៣០ នៃសៀវភៅដដែល ៖

«ពត៌មានបានត្រូវបញ្ជូនទៅដល់ពួកវរជនជាន់ខ្ពស់ទាំងអស់ ថាពួកគេក៏នឹងត្រូវអាមេរិកាំងរំដោះឲ្យចេញមកក្រៅផងដែរ ។ ប៉ុន្តែជាការបណ្តាលឲ្យពួកយើងភ័ន្តភាំងស្រឡាំងកាំង និងមានការអាម៉ាស់ជាខ្លាំង ។ ពួកគេទាំងអស់ដោយរាប់ទាំងប្អូនលោកលន់-នល់ គឺលន់-ណុន ហើយនិងវដ្ឋមន្ត្រីទី១ឡុង-បូរ៉េតផង មិនព្រមចាកចេញទេ ។

ទ្រង់សិរិមតៈបានសរសេរលិខិតមួយមកលោក Dean នៅថ្ងៃទី១២មេសា ៖

«ជំរាបមកឯកឧត្តម និងប្រិយមិត្ត

«ខ្ញុំសូមអរគុណដោយស្មោះ ចំពោះលិខិតឯកឧត្តម ដែលបានធ្វើសំណើឲ្យខ្ញុំរំដោះខ្លួនស្វែងទៅរកសេរីភាព ។ អនិច្ចា... ខ្ញុំមិនអាចចាកចេញដោយរបៀបកំសាកដូចនេះទេ ។ សូមជំរាបចំពោះរូបលោក និងចំពោះប្រទេសដ៏ធំរបស់លោក, ខ្ញុំមិនដែលមានជំនឿម្តងណាសោះ ថាលោកសុខចិត្តបោះបង់ប្រជាជាតិមួយ ដែលបានជ្រើសរើសយកសេរីភាពដូចនេះទេ ។ លោកបានបដិសេធមិនធានាការពារពួកយើង... ហើយរឿងនេះ យើងក៏មិនដឹងធ្វើយ៉ាងដូចម្តេចដែរ ។

«លោកចាកចេញទៅ, ហើយខ្ញុំសូមបន់ស្រន់ឲ្យរូបលោក ព្រមទាំងប្រទេសរបស់លោក បានទទួលសេចក្តីសុខសុភមង្គល នៅក្រោមមេឃលើដីនេះ ។ ប៉ុន្តែសូមលោកកត់ត្រាឲ្យច្បាស់ បើខ្ញុំត្រូវស្លាប់នៅទីកន្លែងនេះ នៅក្នុងប្រទេសដែលខ្ញុំស្រ-ឡាញ់ វាពុំជាការសំខាន់អ្វីទេ ពីព្រោះមនុស្សយើងទាំងអស់គ្នា កើតឡើងហើយតែ

ងតែស្លាប់ទៅវិញជាធម្មតា ។ ខ្លួនខ្ញុំបានធ្វើកំហុសតែមួយគត់ គឺបានជឿពួកអស់លោក (អាមេរិកាំង) ។

«សូមឯកឧត្តមនិងប្រិយមិត្ត មេត្តាទទួលនូវមិត្តភាពដ៏ស្មោះស្ម័គ្រពីរូបខ្ញុំ»

«ស. សិរិមត:» ។

«ពួកខ្មែរក្រហមបានចូលភ្នំពេញនៅថ្ងៃទី១៧មេសា ។ ឡុង-បូរ៉េតត្រូវបានគេពិឃាតចោលភ្លាមមួយរំពេច ជាមួយនិងពួកក្រុមរដ្ឋមន្ត្រីទាំងប៉ុន្មាន ដែលមិនបានចេញមកក្រៅ» ។

«ទ្រង់សិរិមត:បានត្រូវគេបាញ់ត្រង់ក្រពះទឹក ហើយទុកឲ្យស្លាប់ដោយគ្មានពេទ្យព្យាបាល ។ ទ្រង់បានឈឺចាប់ចំនួនបីថ្ងៃ មុននឹងចាកឋានទៅ» ។

(<u>កកន</u> ៖ ស្ដេចសីហនុនៅទីបំផុត បានវិលត្រឡប់ចូលប្រទេសកម្ពុជាវិញ តាមការហៅរបស់ពួកខ្មែរក្រហម ដោយសន្យាឲ្យឡើងធ្វើជា «ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យអស់មួយជីវិត» ។៚

❑ ❑

❑